ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៧.០១៦.០៥៤ ពិសេស

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៦

# សេចក្តីជូនដំណឹង
# ការដាក់ឱ្យអនុវត្តប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា
# របស់ធនាគារជាតិនៃកម្ពុជា

ធនាគារជាតិនៃកម្ពុជាមានក្តីសោមនស្សរីករាយសូមជម្រាបជូនដំណឹងដល់គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុទាំងអស់ឱ្យបានជ្រាបថា ផ្អែកលើប្រកាសស្តីពីការដាក់ឱ្យអនុវត្តកិច្ចសន្យាមេសម្រាប់ប្រតិបត្តិការទទួលទិញវិញ ដើម្បីធានាដល់ប្រតិបត្តិការអន្តរធនាគារក្នុងទីផ្សាររូបិយវត្ថុ ធនាគារជាតិនៃកម្ពុជានឹងដាក់ឱ្យដំណើរការប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (Liquidity-Providing Collateralized Operation-LPCO) ។

ធនាគារជាតិនៃកម្ពុជាបាននិងកំពុងលើកកម្ពស់ការគ្រប់គ្រងសន្ទនីយភាព តាមរយៈការធ្វើទំនើបកម្មការតាមដាននិងព្យាករណ៍សន្ទនីយភាព និងការបន្តអភិវឌ្ឍមូលបត្រអាចជួញដូរបាន (Negotiable Certificate of Deposit-NCD) ។ ក្នុងបរិការណ៍នេះ ធនាគារជាតិនៃកម្ពុជាបានសម្រេចដាក់ឱ្យដំណើរការនូវប្រតិបត្តិការថ្មីមួយគឺការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) ដើម្បីផ្តល់សន្ទនីយភាពជាប្រាក់រៀលតាមការចាំបាច់ដល់គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ ដែលជាភាគីពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយរូបិយវត្ថុ ។

**លក្ខខណ្ឌចាំបាច់នៃប្រតិបត្តិការថ្មីនេះរួមមាន ៖**

- ប្រតិបត្តិការនឹងត្រូវធ្វើឡើងដើម្បីផ្តល់សន្ទនីយភាពជាប្រាក់រៀល ហើយត្រូវធានាពេញលេញដោយការដាក់បញ្ចាំមូលបត្រអាចជួញដូរបានជាប្រាក់រៀលឬប្រាក់ដុល្លារអាមេរិក ។ វិធានការគ្រប់គ្រងហានិភ័យសមស្របនឹងត្រូវអនុវត្តចំពោះមូលបត្រអាចជួញដូរបានជាប្រាក់ដុល្លារអាមេរិក ដើម្បីកាត់បន្ថយហានិភ័យនៃការប្តូររូបិយប័ណ្ណបរទេស (haircut ១០% លើមូលបត្រអាចជួញដូរបានចារឹកជាប្រាក់ដុល្លារអាមេរិក)
- ប្រតិបត្តិការនឹងត្រូវអនុវត្តប្រចាំខែ...



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

- ប្រតិបត្តិការនីមួយៗត្រូវមានកាលវសាន្ត ៣ខែ និងអាចបន្តបានអាស្រ័យលើប្រសិទ្ធភាពនៃការប្រើប្រាស់សន្ទនីយភាពដែលបានទទួល
- អត្រាការប្រាក់ដេញថ្លៃអប្បបរមាសមស្របនិងបរិមាណទឹកប្រាក់ដែលគ្រោងផ្តល់ នឹងត្រូវប្រកាសនៅពេលចាប់ផ្តើមប្រតិបត្តិការ LPCO នីមួយៗ ដោយធនាគារជាតិនៃកម្ពុជានឹងកំណត់បរិមាណផ្តល់សមស្របទៅតាមស្ថានភាពតម្រូវការជាក់ស្តែង ជាពិសេសទៅតាមការទទួលសំណើដេញថ្លៃនៅប្រតិបត្តិការនីមួយៗ និង
- គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុនីមួយៗដែលចូលរួមក្នុងប្រតិបត្តិការ LPCO នឹងតម្រូវឱ្យមានការបង្ហាញពីចំនួនទឹកប្រាក់ដែលមានបំណងចង់ដេញថ្លៃជាមួយនឹងអត្រាការប្រាក់មួយ ។

ធនាគារជាតិនៃកម្ពុជាគ្រោងនឹងធ្វើប្រតិបត្តិការ LPCO ជាលើកទី១ នៅថ្ងៃអង្គារ ទី១៨ ខែតុលា ឆ្នាំ ២០១៦ ។ ធនាគារជាតិនៃកម្ពុជានឹងធ្វើការវិភាគដោយប្រុងប្រយ័ត្នពីលទ្ធផលនិងឥទ្ធិពលនៃប្រតិបត្តិការនីមួយៗ និងកែសម្រួលលក្ខខ័ណ្ឌនានាតាមការចាំបាច់ ដើម្បីធានាប្រសិទ្ធភាពនៃប្រតិបត្តិការថ្មីនេះ ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុដែលមានបំណងចង់ចូលរួមក្នុងប្រតិបត្តិការ LPCO នេះ មកទទួលយកព័ត៌មានលម្អិតពីនាយកដ្ឋានប្រតិបត្តិការនៃធនាគារជាតិនៃកម្ពុជារៀងរាល់ម៉ោងធ្វើការ ។

សូមទំនាក់ទំនងមកធនាគារជាតិនៃកម្ពុជា
អគ្គនាយកដ្ឋានបច្ចេកទេស
នាយកដ្ឋានប្រតិបត្តិការ
លេខទូរស័ព្ទ៖ ០១២ ៩៦ ៩៦ ៤៤/០១១ ៦១ ៤៨ ៣៤
អ៊ីម៉ែល ៖ sveatiny@nbc.org.kh / veatiny@gmail.com